# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦៧ អនក្រ.សម្រ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង
## សម្រាប់រៀបចំប្រារព្ធខួប ២៥ឆ្នាំ នៃការបង្កើត អាយ ស៊ី ស៊ី-អង្គរ
## នៅខេត្តសៀមរាប ថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០១៨

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់រៀបចំប្រារព្ធខួប ២៥ឆ្នាំ នៃការបង្កើត អាយ ស៊ី ស៊ី-អង្គរ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០១៨ ដែលមានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ប្រធាន |
| ២- តំណាងក្រសួងព្រះបរមរាជវាំង | អនុប្រធាន |
| ៣- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |



www.pheakdeylaw.com

៤- តំណាងក្រសួងមហាផ្ទៃ សមាជិក
៥- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
៦- តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក
៧- តំណាងក្រសួងទេសចរណ៍ សមាជិក
៨- តំណាងក្រសួងបរិស្ថាន សមាជិក
៩- តំណាងក្រសួងព័ត៌មាន សមាជិក
១០-តំណាងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ សមាជិក
១១-អភិបាលនៃគណៈអភិបាលខេត្តសៀមរាប សមាជិក
១២-អគ្គនាយកអាជ្ញាធរជាតិអប្សរា សមាជិកអចិន្ត្រៃយ៍។

**ប្រការ២.-**

គណៈកម្មការអន្តរក្រសួងនេះមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ ចាត់ចែង ត្រួតពិនិត្យ សម្របសម្រួលជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរដែនដី
- រៀបចំខ្លឹមសារ ឯកសារ លិខិតបទដ្ឋានរដ្ឋបាល បដាពាក្យស្លោក និងការងារពាក់ព័ន្ធសម្រាប់ពិធី
- រៀបចំគម្រោងចំណាយនៃកិច្ចដំណើរការរៀបចំពិធី
- ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសង្គ្រោះបន្ទាន់
- ទំនាក់ទំនងនិងសហការជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធក្នុងការអញ្ជើញភ្ញៀវ
- អនុវត្តភារកិច្ចផ្សេងៗទៀតទៅតាមភាពចាំបាច់និងការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**ប្រការ៣.-**

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារបន្ថែមតាមការចាំបាច់។

**ប្រការ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ១២ រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែតុលា ឆ្នាំ២០១៨
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com